ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៩ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការកំណត់អត្រាភាគទាន
# បែបបទ និងនីតិវិធីនៃការបង់ភាគទានរបបសន្តិសុខសង្គម
# ផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៤១៦/៣៦៨ចុះថ្ងៃទី០៤ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៣ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៨ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២១៧/០៧៨ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និង ផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន

- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ/បកចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ៤៨៨អនក្រ/បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ១៥អនក្រ.បក. ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីការកែសម្រួលបៀវត្សមូលដ្ឋាន និងការបើកផ្តល់បៀវត្សដល់មន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ១៩៩ អនក្រ.បក ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៣ ស្តីពីបែបបទនៃការទទួលសិទ្ធិ និងកាតព្វកិច្ចទាក់ទងនឹងស្ថានភាពទាំងប្រាំនៃយោធិនអាជីព និងបទប្បញ្ញត្តិដោយឡែកចំពោះនាយទាហានថ្នាក់ឧត្តមសេនីយ៍
- បានឃើញអនុក្រឹត្យលេខ ១៤១ អនក្រ.បក ចុះថ្ងៃទី ២៨ ខែសីហា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលមាត្រា៣០ ជំពូកទី៣ នៃអនុក្រឹត្យលេខ១៩៩អនក្រ.បក ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៣ ស្តីពីបែបបទនៃការទទួលសិទ្ធិ និងកាតព្វកិច្ចទាក់ទងនឹងស្ថានភាពទាំងប្រាំនៃយោធិនអាជីព និងបទប្បញ្ញត្តិដោយឡែកចំពោះនាយទាហានថ្នាក់ឧត្តមសេនីយ៍
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រង និងការប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលបំណងធានាប្រសិទ្ធភាព ស្ថិរភាព និងនិរន្តរភាពនៃការគ្រប់គ្រងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ព្រមទាំងធានាប្រសិទ្ធភាព និងសក្តិសិទ្ធភាពនៃការចំណាយ និងចីរភាពនៃចំណូលថវិការដ្ឋ។

**មាត្រា ២.-**

អនុក្រឹត្យនេះមានគោលដៅកំណត់អត្រាភាគទាន បែបបទ និងនីតិវិធី នៃការបង់ភាគទានរបបសន្តិសុខសង្គម ផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន។

**មាត្រា ៣.-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះ របបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន លើកលែងតែអតីតយោធិនដែលមានឋានន្តរសក្តិថ្នាក់ឧត្តមសេនីយ៍ និងឧត្តមនាវី ដែលត្រូវអនុវត្តដោយអនុលោមតាមអនុក្រឹត្យលេខ១៤១អនក្រ.បក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលមាត្រា៣០ ជំពូកទី៣ នៃអនុក្រឹត្យលេខ១៩៩ អនក្រ.បក ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៣ ស្តីពីបែបបទនៃការទទួលសិទ្ធិ និងកាតព្វកិច្ចទាក់ទងនឹងស្ថានភាពទាំងប្រាំនៃយោធិនអាជីព និងបទប្បញ្ញត្តិដោយឡែកចំពោះនាយទាហានថ្នាក់ឧត្តមសេនីយ៍។

## ជំពូកទី ២
## ការកំណត់អត្រាភាគទានផ្នែកថែទាំសុខភាព

**មាត្រា ៤.-**

ភាគទាននៃរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ ជាបន្ទុករួមគ្នារវាងរដ្ឋ និងសាមីជន។ អត្រាភាគទាននេះ ត្រូវកំណត់ស្មើនឹង ១ (មួយ) ភាគរយ នៃប្រាក់បៀវត្សមូលដ្ឋាន ឬប្រាក់កម្រៃប្រចាំខែរបស់មន្ត្រីសាធារណៈ ដែលក្នុងនោះ÷

- ០,៥០ (សូន្យក្បៀសហាសិប)ភាគរយ ជាបន្ទុករបស់រដ្ឋ
- ០,៥០ (សូន្យក្បៀសហាសិប)ភាគរយ ជាបន្ទុករបស់សាមីជន ។

**មាត្រា ៥.-**

ភាគទាននៃរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ជាបន្ទុករបស់សាមីជន។ អត្រាភាគទាននេះ ត្រូវកំណត់ស្មើនឹង ០,៥០ (សូន្យក្បៀសហាសិប) ភាគរយ នៃប្រាក់សោធនរបស់សាមីជន ដោយមិនរាប់បញ្ចូលប្រាក់បន្ទាប់បន្សំ ឬប្រាក់ឧបត្ថម្ភផ្សេងៗ។

## ជំពូកទី ៣
## ការចុះបញ្ជី និងការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព
### ផ្នែកទី ១
### ការចុះបញ្ជី និងការចេញអត្តសញ្ញាណសមាជិក

**មាត្រា ៦.-**

បេឡាជាតិរបបសន្តិសុខសង្គម (**ប.ស.ស**) ត្រូវចុះបញ្ជីមន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ដូចមានចែងក្នុងមាត្រា៣នៃព្រះរាជក្រឹត្យលេខនស/រកត/០២១៧/០៧៨ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ចូលក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យនៃរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព របស់ **ប.ស.ស**។

**មាត្រា ៧.-**

**ប.ស.ស** ត្រូវចេញលេខអត្តសញ្ញាណសមាជិក **ប.ស.ស** សម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ដោយអនុលោមតាមលេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ។ ដើម្បីអនុវត្តការចេញលេខអត្តសញ្ញាណសមាជិកនេះ ក្រសួង ស្ថាប័ន ឬអង្គភាពពាក់ព័ន្ធមានភារកិច្ច ÷

-ក្រសួងមុខងារសាធារណៈត្រូវផ្តល់ទិន្នន័យមន្ត្រីសាធារណៈ និងទំហំថវិកាភាគទាន តាមក្រសួង ស្ថាប័នមក **ប.ស.ស** ជារៀងរាល់ខែ។

-ក្រសួង ស្ថាប័ន ឬអង្គភាព ដែលគ្រប់គ្រងផ្ទាល់លើមន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ត្រូវផ្តល់ទិន្នន័យមន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និង អតីតយុទ្ធជន និងទំហំថវិកាភាគទាន ដែលមិនស្ថិតក្រោមការគ្រប់គ្រង របស់ក្រសួងមុខងារសាធារណៈមក **ប.ស.ស** ជារៀងរាល់ខែ។

### ផ្នែកទី ២
### ការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព

**មាត្រា ៨.-**

**ប.ស.ស** ត្រូវទូទាត់តាវកាលិកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជនជូនមូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយ **ប.ស.ស** ស្របតាមលក្ខខណ្ឌ បែបបទ និងនីតិវិធីដូចមានចែងក្នុងមាត្រា២១ នៃអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៧ ស្តីពីលក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់តាវកាលិកផ្នែកហានិភ័យការងារ សម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពមន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន។

## ជំពូកទី ៤
## ការគ្រោងថវិកាភាគទាន និងនីតិវិធីបើកផ្ដល់ថវិកាថែទាំសុខភាពជូន ប.ស.ស
### ផ្នែកទី ១
### ការគ្រោងថវិកាភាគទានថែទាំសុខភាព

**មាត្រា ៩.-**

ឥណទានថវិកាភាគទានផ្នែកថែទាំសុខភាពដែលជាបន្ទុករបស់រដ្ឋ ត្រូវគ្រោងក្នុងកញ្ចប់ថវិកាប្រចាំឆ្នាំរបស់ក្រសួងសុខាភិបាល។

**មាត្រា ១០.-**

នៅពេលរៀបចំថវិកាប្រចាំឆ្នាំ ក្រសួងសុខាភិបាល មានកាតព្វកិច្ចគ្រោងឥណទានថវិកាភាគទានថែទាំសុខភាពដែលជាបន្ទុករបស់រដ្ឋ ដោយផ្អែកលើមូលដ្ឋានផែនការក្របខ័ណ្ឌមន្ត្រីសាធារណៈប្រចាំឆ្នាំរបស់ក្រសួងមុខងារសាធារណៈ ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ។

**មាត្រា ១១.-**

ឥណទានថវិការដ្ឋសម្រាប់ភាគទានផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ ដែលជាបន្ទុករបស់សាមីជនដូចមានចែងក្នុងមាត្រា៤នៃអនុក្រឹត្យនេះ ត្រូវគ្រោងក្នុងកញ្ចប់ថវិកាប្រចាំឆ្នាំរបស់ក្រសួង ស្ថាប័ន និងអង្គភាព ដែលគ្រប់គ្រងសាមីមន្ត្រីសាធារណៈ ។

**មាត្រា ១២.-**

ឥណទានថវិការដ្ឋសម្រាប់ភាគទានផ្នែកថែទាំសុខភាពសម្រាប់អតីតមន្ត្រីរាជការ និងអតីតយុទ្ធជនដែលជាបន្ទុកផ្ទាល់របស់សាមីជនដូចមានចែងក្នុងមាត្រា៥នៃអនុក្រឹត្យនេះ ត្រូវគ្រោងក្នុងកញ្ចប់ថវិកាប្រចាំឆ្នាំរបស់សាមីក្រសួង ស្ថាប័ន និងអង្គភាពដែលគ្រប់គ្រងផ្ទាល់លើអតីតមន្ត្រីរាជការ និងអតីតយុទ្ធជន។

### ផ្នែកទី ២
### នីតិវិធីបើកផ្ដល់ថវិកាថែទាំសុខភាព

**មាត្រា ១៣.-**

ក្រសួង ស្ថាប័ន ឬអង្គភាព គ្រប់គ្រងផ្ទាល់លើមន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ត្រូវបោះអាណត្តិបើកប្រាក់ភាគទានផ្នែកថែទាំសុខភាពដែលជាបន្ទុករបស់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ នឹងអតីតយុទ្ធជន ស្របគ្នានឹងអាណត្តិបើកប្រាក់បៀវត្សប្រចាំខែ ដើម្បីបង្វែរចូលក្នុងគណនីរបស់ **ប.ស.ស** នៅរតនាគារជាតិ ។

**មាត្រា ១៤.-**

ក្រសួងសុខាភិបាល ដោយផ្អែកតាមការស្នើសុំរបស់ **ប.ស.ស** ត្រូវបោះអាណត្តិបើកប្រាក់ប្រចាំត្រីមាសដើម្បីបង្វែរសាច់ប្រាក់ភាគទានថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជនដែលជាបន្ទុករបស់រដ្ឋ មកចូលក្នុងគណនីប្រាក់បញ្ញើរបស់ **ប.ស.ស** នៅរតនាគារជាតិ ។

**មាត្រា ១៥.-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អាចចេញប្រកាសស្ដីពីនីតិវិធីអនុវត្តថវិកាលម្អិតបន្ថែម តាមការចាំបាច់ ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តថវិកាភាគទានថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជននេះ។

## ជំពូកទី ៥
## អន្តរប្បញ្ញត្តិ

**មាត្រា ១៦.-**

ភាគទាននៃរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ដែលជាបន្ទុករបស់សាមីជនដូចមានចែងក្នុងមាត្រា៤ និងមាត្រា៥ នៃអនុក្រឹត្យនេះ ត្រូវរ៉ាប់រងបង់ជំនួសដោយរាជរដ្ឋាភិបាល រហូតដល់មានការសម្រេចជាថ្មី។

## ជំពូកទី ៦
## អវសានប្បញ្ញត្តិ

**មាត្រា ១៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីគ្រប់ក្រសួង នាយកបេឡាជាតិរបបសន្តិសុខសង្គម ប្រធានគ្រប់ស្ថាប័ន និងអង្គភាពពាក់ព័ន្ធទាំងរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃសុក្រ ៩ រោច ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស ២៥៦១

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៩ ខែមករា ឆ្នាំ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** សូមហត្ថលេខា

| | | |
|---|---|---|
| **ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី** | **រដ្ឋមន្ត្រី** | **រដ្ឋមន្ត្រី** |
| **ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** | **ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ** | **ក្រសួងសុខាភិបាល** |
| **អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** | **អ៊ិត សំហេង** | **ម៉ម ប៊ុនហេង** |

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៨
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ